**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១១១/០១១/២០០៦

ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**សេចក្តីសម្រេច**

លេខ : ០៨២/០០៩/២០០៦ កបធ.ច

ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៦

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៦/០២៥ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ
- បានឃើញលិខិតលេខ តរ.ករម.៣០/០៦ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០០៦ របស់ឯកឧត្តម លោកជំទាវតំណាងរាស្ត្រ ចំនួន ១៦ រូប ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមាត្រា ៩ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០០៦ វេលាម៉ោង ០៩ : ៣០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា សំណើរបស់ឯកឧត្តម និង លោកជំទាវតំណាងរាស្ត្រ ចំនួន ១៦រូប ស្របតាមលក្ខខ័ណ្ឌនៃមាត្រា ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន ។

- យល់ឃើញថា អភ័យឯកសិទ្ធិសភាត្រូវបានផ្តល់ជូនរដ្ឋសភា ។
- យល់ឃើញថា តំណាងរាស្ត្រគ្រប់រូបមានអភ័យឯកសិទ្ធិសភា ដែលធានាមិនឱ្យតំណាងរាស្ត្របារម្ភអំពីការរំលោភបំពានពីសំណាក់អំណាចនីតិប្រតិបត្តិ ឬ អំណាចតុលាការ ។ ប៉ុន្តែអភ័យឯកសិទ្ធិនេះ ក៏មានព្រំដែនកំណត់ដែរ ។
- យល់ឃើញថា មាត្រា ៩ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ មានខ្លឹមសារគ្រើនរំឭកដល់តំណាងរាស្ត្រ ហើយពុំមានធ្វើឱ្យតំណាងរាស្ត្របាត់បង់អភ័យឯកសិទ្ធិសភារបស់ខ្លួនឡើយ។

## សម្រេច

**មាត្រា ១.-** ផ្អែកតាមមូលបទខាងលើ មាត្រា ៩ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៦/០២៥ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៦ ពុំមានអធម្មនុញ្ញភាពទេ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៦

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ទិន ឈិន